សួស្តីមិត្តភក្តិទាំងអស់គ្នា ជួបជាមួយខ្ញុំម្តងទៀតហើយនៅក្នុងការបកស្រាយអំពីរដូវភ្លៀង។ បាទ អាកាសធាតុនៅក្នុងប្រទេសកម្ពុជា គឺមានលក្ខណៈក្តៅហើយសើម។ បាទ នៅក្នុងនោះដែរគឺគេបែងចែក រដូវក្តៅហើយនឹងរដូវភ្លៀង។ បាទ រដូវភ្លៀងគឺមានលក្ខណៈ បាទ រដូវភ្លៀងគឺមានលក្ខណៈ ៣ ខែ បាទ រីឯ ៣ ខែទៀតមានលក្ខណៈធ្លាក់ខ្យល់ រីឯ ៦ ខែទៀតគឺមានលក្ខណៈសភាពក្តៅហើយសើម។ បាទ រដូវភ្លៀងគឺចាប់ពីខែសីហា កញ្ញា តុលា បាទ តែ ៣ ខែទេ គឺមានលក្ខណៈធ្លាក់ភ្លៀងច្រើន។ បាទ បើសិនជាយើងគិតថាវាធ្លាក់ភ្លៀងច្រើន វាធ្លាក់ភ្លៀងច្រើននៅចន្លោះខែ ខែសីហា និងខែតុលា បាទ រីឯខែតុលាវិញ មិនសូវជាមានធ្លាក់ភ្លៀងទេ។ បាទ ពេលដែលធ្លាក់ភ្លៀង[?]អញ្ចឹង [...] វាផ្តល់ផលប្រយោជន៍ ទៅឲ្យការដាំដុះស្រូវ បាទ ការដាំដុះស្រូវ ក៏ដូចជា ផលដំណាំផ្សេងៗ។ ប៉ុន្តែវាផ្តល់ផលអាក្រក់ទៅដល់សង្គម ដូចជានៅទីក្រុង បាទ ដូចជានៅទីក្រុង ក៏ដូចជានៅកន្លែងដែលអភិវឌ្ឍ។ បាទ វាធ្វើឲ្យនៅកន្លែងនោះលិចទឹក បាទ ស្អុយសំរាម បាទ ពេលដែលវាលិចទឹកអញ្ចឹងទៅសំរាមវាអណ្តែតនៅលើទឹក អញ្ចឹងទៅធ្វើឲ្យស្អុយ។ បាទ ហើយកត្តាមួយទៀតហ្នឹង វាធ្វើឲ្យលូហ្នឹងវាមានលក្ខណៈស្ទះ បាទ លូហ្នឹងវាមានលក្ខណៈស្ទះ ហើយអញ្ចឹងទៅវាធ្វើឲ្យបរិស្ថានហ្នឹងគឺវាកខ្វក់តាមហ្នឹងដែរ។ បើសិនជាលូស្ទះហើយ [...] ពេលដែលយើងធ្វើដំណើរទៅមកហ្នឹង វាធ្វើឲ្យមានការ បាទ ឡើងទឹក [...] ត្រឹមជង្គង់យើង [...] ឬមួយក៏ត្រឹមចង្កេះ[...] ធ្វើឲ្យយើងមានការពិបាកក្នុងការធ្វើដំណើរទៅមកៗ បាទ ហើយក៏មានការផ្តល់ឲ្យ[...] មានលក្ខណៈយឺត បាទ ព្រោះថាយើងចង់ទៅណាមួយ យើងមាន យើងចង់បានទៅទីនោះលឿន ប៉ុន្តែពេលដែលមានបញ្ហាលិចទឹកហើយ គឺវាធ្វើឲ្យយើងហ្នឹង បង្កើនភាពយឺតទៅវិញ បាទ បង្កើនភាពយឺតទៅវិញ។ ដូច្នេះវាមិនមានផលល្អ ពេលដែលមានទឹកឡើង ឬមួយក៏ភ្លៀងខ្លាំងនោះទេ។ បាទ នៅក្នុងទីក្រុងភ្នំពេញ ក៏ដូចជានៅខេត្តសៀមរាប ប្រសិនជាមានភ្លៀងធ្លាក់មួយមេ ឬមួយក៏ពីរមេ ដូច្នេះគឺធ្វើឲ្យយើងហ្នឹង មានលក្ខណៈ ដូចថា ភ្លៀងខ្លាំងពីរ បីមេអីជាប់គ្នាអញ្ចឹងទៅ ធ្វើឲ្យយើងហ្នឹងមានការលំបាកមែនទែន ព្រោះថាពេលដែលមានភ្លៀងម្តងៗ គឺមានលក្ខណៈ ដូចថានៅតំបន់ខ្លះ គឺវាលិចទឹក បាទ ហើយយើងយ៉ាប់ធ្វើដំណើរ។ ហើយពេលដែលលិចទឹកនោះ គឺវាមិនបានផ្តល់ចំណេញអីទេនៅទីក្រុង ប៉ុន្តែវាបានបំផ្លាញទៅវិញ បាទ បំផ្លាញយ៉ាង[មិច?] គឺ ពេលដែលភ្លៀងមក គឺវាបំផ្លាញផ្លូវ បាទ វាធ្វើឲ្យបាក់ផ្លូវ វាធ្វើឲ្យស្រុតដី បាទ វាធ្វើឲ្យយើងហ្នឹងយ៉ាប់ធ្វើដំណើរ បាទ ហើយដីវិញគឺថាទន់[...]រអៀច បាទ ប្រឡាក់ជើងប្រឡាក់ដៃ អ្នកខ្លះក៏មានការគ្រោះថ្នាក់ចរាចរណ៍ដោយសារតែ ទឹកជំនន់ ឬមួយក៏ទឹកភ្លៀងនេះ។ ពេលដែលភ្លៀងវាមក វាបិទភ្នែកយើងជិត ពេលដែលយើងជិះម៉ូតូទៅ វាបិទភ្នែកយើងជិត យើងមិនអាចមើលម៉ូតូ នៅខាងមុខ ក៏ដូចជាឡាននៅខាងមុខ ដែលយើងនៅទីនោះឃើញទេ។ បាទ ហើយនៅទីក្រុង បាទ គឺថាមានលក្ខណៈយ៉ាប់មែនទែន ពេលដែលនៅទីក្រុង [...] ទាំងប្រជាជន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អីនៅក្នុងទីក្រុង គឺមានលក្ខណៈយ៉ាប់ទាំងអស់ ព្រោះថាប្រជាជននៅខាងក្នុងទីក្រុងភាគច្រើនគឺគេធ្វើការ គឺគេប្រកបមុខរបរហើយនិងរកស៊ី បាទ ក៏ដូចជារកស៊ីពេលយប់ ឬមួយក៏ពេលថ្ងៃអញ្ចឹងទៅ។ បើសិនជាមានភ្លៀងធ្លាក់មក អញ្ចឹងការលក់ដូររបស់គេហ្នឹង នឹងមិនសូវដាច់ បាទ មិនសូវដាច់។ ហើយមានពាក្យខ្មែរមួយឃ្លាទៀតនោះគេថា ខែភ្លៀងគឺជាខែពោះគោពោះក្របី។ បាទ វាពិតមែនព្រោះថាខែគោ ខែពោះគោពោះក្របីហ្នឹង ប្រៀបធៀបទៅនឹង ដូចថា ខែភ្លៀងហ្នឹង គឺជាខែអត់ បាទ ខែអត់ឃ្លាន ព្រោះថាខែហ្នឹង យើងរកវាមិនសូវបាន បាទ យើងរកលុយវាមិនសូវបាន ហើយយើងចេះតែចំណាយច្រើន។ បាទ ព្រោះថាឲ្យតែពេលភ្លៀងអញ្ចឹងយើងឃ្លាន យើងចេះតែញ៉ាំ ប៉ុន្តែការរកចំណូល ការរកលុយរបស់យើង មានលក្ខណៈយឺត មានលក្ខណៈដូចថា យើងចាយច្រើនជាងចំណូលរបស់យើង។ ឧទាហរណ៍ថា យើង មួយថ្ងៃយើងរកលុយបានចំនួន ៥ ដុល្លារ ប៉ុន្តែក្រុមគ្រួសាររបស់យើងហ្នឹង គឺចាយលុយអស់ចំនួន ១០ ដុល្លារ អីអញ្ចឹងទៅ ដូច្នេះវាធ្វើឲ្យមានបញ្ហាក្រុមគ្រួសារ ជីវភាពក្នុងក្រុមគ្រួសារអីអញ្ចឹងទៅ។ បាទ ហើយនៅខាងក្នុងក្រុងមួយទៀត គឺពេលដែលមានភ្លៀងម្តងៗ គឺដូចថា ប្រជាជនភាគច្រើនគឺនៅផ្ទះ មានការងារអីដែលត្រូវធ្វើហ្នឹង គឺមិនបានភ្លាមៗនោះទេ គឺបង្អាក់ពេលវេលា។ ដូច្នេះខ្ញុំសូមបញ្ចប់នូវការបកស្រាយ នូវរដូវភ្លៀងតែត្រឹមប៉ុណ្ណេះសិន។ បាទ សូមអរគុណ សូមជម្រាបលា។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.